ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៣៦៤

ចុះថ្ងៃទី០៤-០៦-២០១៩

-សំណុំរឿងជំនុំជម្រះ

លេខ ៤៩៣១

ចុះថ្ងៃទី១៣-១២-២០១៩

-សាលក្រមព្រហ្មទណ្ឌ

លេខ ១២៣៩ "ច១" ក្រ១០

ចុះថ្ងៃទី ០៣-១១-២០២០

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង០២ និង៣០ នាទី រសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

១.ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៦៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ ដែលមានសាវតាជាតិជនជាប់ចោទ ដូចខាងក្រោម៖

១.១.ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ហៅ ថា ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិសែនសុខ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ភូមិសែនសុខទី១ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២៣១ "អ" ដ.យ.ដ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩។ (ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ "ម១" នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ)

១.២.ជនជាប់ចោទឈ្មោះ [redacted] រៈ ហៅ រៈ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតភូមិស្ពែ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២៣២ "អ" ដ.យ.ដ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩។ (ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ "ម១" នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ)

ជាប់ចោទពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាគ្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិគ្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.៣.ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណា ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃស្នាក់ [redacted] សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រស់” ម្តាយឈ្មោះ [redacted] “រស់” ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៥២៣៩ “ច១” ដ.ឃ.ដ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។ (ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ “ម១” នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ)

១.៤.ជនជាប់ចោទឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted] សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រស់” ម្តាយឈ្មោះ [redacted] “រស់” ជានីតិជន។ (ក្រៅឃុំ)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៦២១ ដ.ច.ន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ។

១.៥.ជនជាប់ចោទឈ្មោះ [redacted] ហៅ តា ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ [redacted] ភូមិសែនសុខទី៤ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “ស្លាប់” ម្តាយឈ្មោះ [redacted] “រស់” ជានីតិជន។ (ក្រៅឃុំ)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៦២២ ដ.ច.ន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ។

១.៦.ជនជាប់ចោទឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរកាប់ជ្រូកលក់ ទីកន្លែងកំណើតភូមិប្រាសាទ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់ [redacted] សែនសុខ៤ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រស់” ម្តាយឈ្មោះ [redacted] “រស់” នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

-ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៦២៦១ ដ.ព.ស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩។

១.៧.ជនជាប់ចោទឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted] CP២១ ផ្លូវលេខ២៤៤ ភូមិសែនសុខ៣ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “ស្លាប់” ម្តាយឈ្មោះ [redacted] រស់” ជានីតិជន។ (ក្រៅឃុំ)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៨១៧ ដ.ច.ន ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ។

១.៨.ជនជាប់ចោទឈ្មោះ [redacted] សុភក្តី ហៅ ចូ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ភូមិសែនសុខសុខទី៤ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រស់” ម្តាយឈ្មោះ [redacted] “រស់” ជានីតិជន។ (ក្រៅឃុំ)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨១៦ ដ.ច.ន ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ។

១.៩.ជនជាប់ចោទឈ្មោះ [redacted] ផានិត ហៅ ភ្និត ភេទប្រុស កើតនៅឆ្នាំ១៩៩៦ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃបន្ទប់ជួលផ្ទះ [redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រស់” ម្តាយឈ្មោះ [redacted] “រស់” ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ជានីតិជន។ (ក្រៅឃុំ)



Scanned with CamScanner

ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្ត នៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] សុខវណ្ណា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានការិយាល័យភូមិរោងចក្រ ១ មហាវិថីហាណូយ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លីប៊ាង ហៅ ប៊ាង ។

-លោកមេធាវី [redacted] ច័ន្ទសុវណ្ណដា អត្តលេខ២០៤៩T មានមាការិយាល័យមេធាវី ផ្ទះលេខ៤២០ ផ្លូវ ៣៧១ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សុវណ្ណា ។

-លោកមេធាវី [redacted] សុគាណា អត្តលេខ៨៣៦ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅថា ឈ្មោះ [redacted] រៈ ហៅ រៈ ឈ្មោះ [redacted] ហេង ហៅ ស្រីហេង, ឈ្មោះ [redacted] សុភា ហៅ ភា, ឈ្មោះ [redacted] លីប៊ាង ហៅ ហាង, ឈ្មោះ [redacted] ស្វិត ហៅ ស្វិត, ឈ្មោះ [redacted] សុភក្តី ហៅ ធូ ,ឈ្មោះ [redacted] ផានិត ហៅ ក្និត ។

១.១០.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល ផ្លូវបេតុង ភូមិរកា ឃុំឫស្សីស្រុក ស្រុកអង្គស្នួល ខេត្តកណ្តាល។

## ២.អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង០៤ និង០០នាទីទៀបភ្លឺ នៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញក មានករណីលួចមានស្ថានទម្ងន់ទោដោយសារការប្រព្រឹត្តអំពើហិង្សា មួយបានកើតឡើងដែលបង្កដោយជនជាប់ចោទចំនួន ១០នាក់ ១.ឈ្មោះ [redacted] វណ្ណា ហៅ ថា ភេទប្រុស អាយុ១៨ឆ្នាំ ២.ឈ្មោះ [redacted] រៈ ភេទប្រុស អាយុ២៨ឆ្នាំ ៣.ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ ៤.ឈ្មោះ [redacted] ស្វិត ភេទប្រុស អាយុ២៣ឆ្នាំ ៥.ឈ្មោះ [redacted] លីប៊ាង ហៅ ប៊ាង ភេទប្រុស អាយុ២២ឆ្នាំ ៦.ឈ្មោះ [redacted] សុភក្តី ហៅ ធូ ភេទប្រុស អាយុ២៣ឆ្នាំ ៧.ឈ្មោះ [redacted] សុវណ្ណា ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ ៨.ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ហៅ ហេង ភេទប្រុស អាយុ២៦ឆ្នាំ ៩.ឈ្មោះ [redacted] ផានិត ហៅ ក្និត ភេទប្រុស អាយុប្រហែល២៤ឆ្នាំ ១០.ឈ្មោះ ហុង ភេទប្រុស អាយុប្រហែល១៧ឆ្នាំ បានធ្វើសកម្មសកម្មភាពយកកាំបិតផ្គាក់ប្រវែងប្រហែលកន្លះម៉ែត្រ កាប់មកលើជនរងគ្រោះឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ៣១ឆ្នាំ។ ដោយនៅមុនពេលកើត ហេតុជនរងគ្រោះបានជិះម៉ូតូម៉ាកសេ១២៥ សេរី០១៧ ពណ៌ខ្មៅ ពាក់ស្លាក់លេខកណ្តាល 1W-0477 លេខតួ-លេខម៉ាស៊ីន ៨៧៧៨៦៣៥ ធ្វើដំណើរតាមបណ្តោយផ្លូវទំនប់កប់ស្រូវ(មហាវិថីវិមានឈ្នះ១) ទិសដៅពីលិចទៅកើត មកដល់ចំណុចកើតហេតុខាងលើ ពេលនោះជនជាប់ចោទឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] រៈ ភេទប្រុស អាយុ២៨ឆ្នា និងបក្ខពួកចំនួន០៨នាក់ទៀតមាន ឈ្មោះខាងលើបានឃើញជនរងគ្រោះជិះម៉ូតូតែម្នាក់ឯង ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] ហេង បានបន្ថែមល្បឿនម៉ូតូបើកទៅអែបទន្ទឹមម៉ូតូរបស់ជនរងគ្រោះ ហើយជនជាប់ចោទឈ្មោះ [redacted] សុភា បានលើកកាំបិតផ្គាក់កាប់មកលើជនរងគ្រោះពីក្រោយបណ្តាលឱ្យជនរងគ្រោះរបួសស្រាល មានស្នាមដាំ ឆូតចំនួន០២កន្លែងនៅលើខ្នង រួចជនរងគ្រោះបានដួលម៉ូតូ ហើយក៏ស្ទុះងើបរត់គេចខ្លួនចេញពីកន្លែងកើតហេតុ ឃើញដូចនេះជនជាប់ចោទឈ្មោះ [redacted] សុភា ក៏បានចុះពីលើម៉ូតូ ហើយលើកយកម៉ូតូរបស់ជនរងគ្រោះជិះគេចខ្លួន ចំណែកឯបក្ខពួកបានជិះម៉ូតូបិទគូថ ហើយក៏គេចខ្លួនបាត់តែម្តង។ បន្ទាប់ពីកើតហេតុរួចមកជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្មួញ។ លុះដល់



Scanned with CamScanner

ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២២ និង៣០នាទី សមត្ថកិច្ចបានធ្វើការស្រាវជ្រាវរួចឃាត់ខ្លួនបានជនជាប់ចោទចំនួន០២នាក់ឈ្មោះ[redacted]រៈ ភេទប្រុស អាយុ២៨ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] វដ្ដា ភេទប្រុស អាយុ១៨ឆ្នាំ យកមកអធិការដ្ឋាននគរបាលខណ្ឌសែនសុខដើម្បីធ្វើការសាកសួរ និងបានធ្វើតេស្ដិ៍ស្វែងរកសារធាតុញៀនជាលទ្ធផល វិជ្ជមាន ទើបសមត្ថកិច្ចបញ្ជូនជាប់ចោទទាំងពីរនាក់មកតុលាការដើម្បីចាត់ការតាមនីតិវិធី។

២.១.បានឃើញរបាយការណ៍លេខ០៨៥/១៩ រ.ប.ក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ។

២.២.បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២២៥៥ អ.យ.ជ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.៣.បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៨០៨ អ.យ.ជ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.៤.បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦១៥៨ "អ" ង.ជ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## ៣.ការពលសចនាការ

៣.១.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]វដ្ដា ហៅ ថា បានឆ្លើយថា៖ ចំពោះការចោទប្រកាន់របស់តំណាងអយ្យការខ្លួនទទួល ខ្លួនទើបតែប្រព្រឹត្តជាលើកទី១ទេ មូលហេតុពេលនោះខ្លួន និងបក្ខពួកទើបតែមកពីប្រើប្រាស់ថ្នាំញៀនរួចបាត់បង់ស្មារតី។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀន ចំនួន០២ឆ្នាំហើយ។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង១២យប់ ខ្លួនចូលរាំលេងក្នុងក្លឹបហ្សូន ម្ដុំផ្សារដីហុយ សង្កាត់ភ្នំពេញថ្មី ក្រោយពីរាំលេងនៅក្នុងក្លឹបរួចក៏ត្រឡប់មកផ្ទះ បានជួបនឹងឈ្មោះ ហេង ឈ្មោះ ភា នៅលើទំនប់កប់ស្រូវកំពុងធ្វើសកម្មភាពកាប់ជនរងគ្រោះប្លន់យកម៉ូតូតែម្ដង ហើយពេលនោះខ្លួនក៏ជិះម៉ូតូត្រឡប់ក្រោយវិញ។ ចំពោះឈ្មោះ [redacted]សុវណ្ណ ហៅ ហ្គិច កន្ទួងមកខ្ញុំពុំដែលស្គាល់ និងឃើញវាទេ ហើយនៅថ្ងៃកើតហេតុនោះ គឺពុំបានឃើញ វាធ្វើសកម្មភាពជាមួយឈ្មោះ ហេង និងភាឡើយ។

៣.២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]រៈ ហៅ រៈ បានឆ្លើយថា៖ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង០៦ល្ងាច ខ្លួននិងបក្ខពួកប្រហែល១០នាក់ បានជួបជុំគ្នាប្រើប្រាស់ថ្នាំញៀន នៅក្នុងផ្ទះសំណាក់នាគទិព្វ ក្រោយពេលប្រើប្រាស់ថ្នាំញៀនរួច ខ្លួននិងបក្ខពួកក៏បានជិះម៉ូតូដើរលេង ក៏បានជួបជនរងគ្រោះ កំពុងជិះម៉ូតូតែម្នាក់ឯង និងបក្ខពួកក៏ធ្វើសកម្មភាពប្លន់យកម៉ូតូជនរងគ្រោះតែម្នាក់ឯង។ ឈ្មោះ ហុង ភេទប្រុស អាយុ១៧ឆ្នាំ មានទីលំនៅផ្ទះជួលម្ដុំផ្សារ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ និងឈ្មោះ ក្អិត ភេទប្រុស អាយុប្រហែល២៣ឆ្នាំ ស្នាក់នៅផ្ទះជួលម្ដុំផ្សារសាំបាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ។ ចំពោះឈ្មោះ[redacted] សុវណ្ណ ហៅ ហ្គិច កន្ទួងមកខ្ញុំពុំដែលស្គាល់ និងឃើញវាទេ ហើយនៅថ្ងៃកើតហេតុនោះ គឺពុំបានឃើញ វាធ្វើសកម្មភាពជាមួយឈ្មោះ ហេង និងភាឡើយ។

៣.៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សុវណ្ណ ហៅ ហ្គិច បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្ញុំនៅផ្ទះ ពុំបានចូលរួមធ្វើកម្មភាពជាមួយពួកនោះទេ។ ចំពោះឈ្មោះ[redacted]វដ្ដា ហៅថា ឈ្មោះ[redacted]រៈ ហៅ រៈ ឈ្មោះ[redacted] ហេង ហៅ ស្រីហេង, ឈ្មោះ[redacted] សុភា ហៅ ភា, ឈ្មោះ[redacted] លីប៉ាង ហៅ ប៉ាង, ឈ្មោះ [redacted]ស្វិត ហៅ ស្វិត, ឈ្មោះ[redacted] សុភក្ដី ហៅ ធូ ,ឈ្មោះ [redacted]ានិត ហៅ ក្អិត ខ្ញុំបាទពុំស្គាល់ពួកគេនោះទេ។ ខ្ញុំមានតែឪពុកម្ដាយរបស់ខ្ញុំទេ ដែលជាសាក្សីអាចបញ្ជាក់ថាខ្ញុំមិនបានចូលរួមធ្វើសកម្មភាពជាមួយពួកនោះ។



Scanned with CamScanner

៣.៤.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីប៊ាង ហៅ ប៊ាង នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ចំពោះការចោទប្រកាន់របស់តំណាងអយ្យការនេះ ខ្លួនពុំទទួលយកទេ ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ នៅយប់ថ្ងៃកើតហេតុថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ខ្លួននៅសម្រាក់នៅផ្ទះ ដោយពុំបានចេញដើរលេងជាមួយក្រុមនេះទេ។ ហើយកន្លងមកខ្លួនជាមួយនឹងក្រុមនេះ ពុំដែលមានទំនាក់ទំនងអ្វីនឹងគ្នាឡើយ។ រាល់ព្រឹកចាប់តាំងពីម៉ោង៣ទាប់ភ្លឺ ខ្លួនត្រូវងើបចាក់កជ្រូក កោសជ្រូកទុកលក់ជូនអាជីវករ ពុំដែលមានពេលទំនេរនោះទេ។ ម្យ៉ាងទៀតការដែលតុលាការធ្វើការចោទប្រកាន់នោះក៏ពុំចំឈ្មោះ របស់ខ្លួនដែរ គឺតុលាការចោទលើឈ្មោះ [redacted] លីហេង ហៅ ហាង ចំណែកខ្លួនឈ្មោ [redacted] លីប៊ាង ភេទប្រុស អាយុ២២ឆ្នាំ។ ខ្លួនមានសាក្សីពីរនាក់ឈ្មោះ [redacted] ថាវី ភេទប្រុស អាយុប្រហែល២៧ឆ្នាំ និងឈ្មោះ [redacted] គី ភេទប្រុស អាយុប្រហែល៣៥ឆ្នាំ ដែលបញ្ជាក់ថាយប់កើតហេតុ ខ្លួន និងពួកគាត់ពិតជានៅកន្លែងធ្វើជ្រូកជាមួយគ្នា។ ខ្លួនសុំឱ្យតុលាការធ្វើការលើកលែងចោទប្រកាន់លើខ្លួន។

៣.៥.ក្រឡាបញ្ជីអានកំណត់ហេតុបណ្តឹងរបស់ឈ្មោះ [redacted] ស៊ីណាត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩។

៣.៦.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ និងរបាយការណ៍របស់សមត្ថកិច្ចព្រមទាំងភស្តុតាងផ្សេងៗដែលមានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] រ: ហៅ រ: ភេទប្រុស អាយុ២៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ ,ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ២៦ឆ្នាំ, ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] លីប៊ាង ហៅ ប៊ាង ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទប្រុស អាយុ២៣ឆ្នាំ, ឈ្មោះ [redacted] សុភក្តី ហៅ ធូ ភេទប្រុស អាយុ២៣ឆ្នាំ ,ឈ្មោ [redacted] ផានិត ហៅ ក្និត ភេទប្រុស អាយុ២៣ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំឱ្យលោកចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៣.៧.លោកមេធាវី [redacted] សុវណ្ណដា ការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ តាមចម្លើយរបស់កូនក្តីខ្ញុំបដិសេធការចោទប្រកាន់មកលើរូបខ្លួន និងចម្លើយរបស់ជនជាប់ចោទឈ្មោ [redacted] រដ្ឋា និងឈ្មោះ [redacted]: បានឆ្លើយថាមិនបានស្គាល់ឈ្មោ [redacted] សុវណ្ណពីមុនមកដែរ នេះសបញ្ជាក់ឱ្យឃើញថានៅក្នុងរឿងក្តីនេះកូនក្តីខ្ញុំពុំមានអ្វីពាក់ព័ន្ធទៅអង្គហេតុដែលតំណាងអយ្យការចោទប្រកាន់នោះឡើយ គឺនៅថ្ងៃកើតហេតុកូនក្តីរបស់ខ្ញុំចេញពីធ្វើការទៅផ្ទះប្អូនឈ្មោះ មិនបានចូលរួមធ្វើកម្មភាពលួចមានស្ថានទម្ងន់ទោសនោះទេ។ ដោយជាវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ហេតុនេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ។

៣.៨.លោកមេធាវី [redacted] សូតាណា ការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាក្នុងអង្គសវនាការ ឃើញថាកូនក្តីរបស់ខ្ញុំឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] រ: បានឆ្លើយថាពិតជាបានឃើញឈ្មោះ ហេង និងឈ្មោះ ភា ប្រើហិង្សាទៅលើជនរងគ្រោះ ប៉ុន្តែខ្លួនមិនបានធ្វើសកម្មភាពជួយនោះទេ



Scanned with CamScanner

នេះសបញ្ជាក់ឱ្យថាឈ្មោះ[redacted] រដ្ឋា និងឈ្មោះ [redacted]រៈ ពុំបានពាក់ព័ន្ធក្នុងអង្គហេតុនេះឡើយ។ រីឯជនឈ្មោះ ឈ្មោះ[redacted]សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ , ឈ្មោះ [redacted]ស្វិត ហៅ ស្វិត ភេទប្រុស អាយុ២៣ឆ្នាំ, ឈ្មោះ [redacted]សុភក្តិ ហៅ ធូ ភេទប្រុស អាយុ២៣ឆ្នាំ ,ឈ្មោះ[redacted] ផានិត ហៅ ក្ងិត ភេទប្រុស អាយុ២៣ឆ្នាំ ខ្ញុំបាទជាមេធាវីពុំអាចទាក់ទងបានឡើយ ប៉ុន្តែដោយសារក្នុងរឿងក្តីនេះ ពុំបានបណ្តាលឱ្យជនរងគ្រោះមានរបួសធ្ងន់ធ្ងរនោះទេ ហេតុនេះស្នើសុំក្រុមប្រឹក្សាសម្រេចតាមច្បាប់ និងផ្តល់ស្ថានសម្រាលទោសជាអប្បរមាដោយក្តីអនុគ្រោះ។

៣.៩.ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បាននិយាយសំដីចុងក្រោយបង្អស់ថា សុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង និងសុំដោះលែងខ្លួនឱ្យមានសេរីភាពវិញ។

៣.១០.ជនជាប់ចោទឈ្មោះ [redacted]ដ្ឋាន ឈ្មោះ[redacted]: បាននិយាយសំដីចុងក្រោយបង្អស់ថា សុំឱ្យតុលាការ តុលាការបន្ធូរបន្ថយទោសឱ្យពួកខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនចោទ។

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ។

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## ៤.សំអាងហេតុ

៤.១.តាមរបាយការណ៍ ០៨៥/១៩ រ.ប.ក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានសន្និដ្ឋានថា៖ ឈ្មោ[redacted]រដ្ឋា ភេទប្រុស អាយុ១៨ឆ្នាំ, ឈ្មោះ[redacted]រៈ ហៅ រៈ ភេទប្រុស អាយុ២៨ឆ្នាំ, ឈ្មោះ[redacted]ហេង ហៅ ស្រីហេង ភេទប្រុស អាយុ២៦ឆ្នាំ, ឈ្មោះ[redacted] សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted]សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ[redacted]លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted]ស្វិត ហៅ ស្វិត ភេទប្រុស អាយុប្រហែល២៤ឆ្នាំ និងឈ្មោះ ហុង ភេទប្រុស អាយុ១៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ប្រើកាំបិតផ្គាក់កាប់យកម៉ូតូ) នៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ឆ្នាំ ខែឧសភា ឆ្នាំ២០១៩ ពិតប្រាកដមែន។

៤.២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]រដ្ឋា ហៅ ថា បានឆ្លើយថា៖ ចំពោះការចោទប្រកាន់របស់តំណាងអយ្យការខ្លួនទទួល ខ្លួនទើបតែប្រព្រឹត្តជាលើកទី១ទេ មូលហេតុពេលនោះខ្លួន និងបក្ខពួកទើបតែមកពីប្រើប្រាស់ថ្នាំញៀនរួចបាត់បង់ស្មារតី។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀន ចំនួន០២ឆ្នាំហើយ។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង១២យប់ ខ្លួនចូលរាំលេងក្នុងក្លឹបហ្សូន ម្តុំផ្សារដីហុយ សង្កាត់ភ្នំពេញថ្មី ក្រោយពីរាំលេងនៅក្នុងក្លឹបរួចក៏ត្រឡប់មកផ្ទះ បានជួបនឹងឈ្មោះ ហេង ឈ្មោះ ភា នៅលើទំនប់កប់ស្រូវកំពុងធ្វើសកម្មភាពកាប់ជនរងគ្រោះប្លន់យកម៉ូតូតែម្តង ហើយពេលនោះខ្លួនក៏ជិះម៉ូតូត្រឡប់ក្រោយវិញ។ ចំពោះឈ្មោះ [redacted]សុវណ្ណ ហៅ ហ្គិច កន្លងមកខ្ញុំពុំដែលស្គាល់ និងឃើញវាទេ ហើយនៅថ្ងៃកើតហេតុនោះ គឺពុំបានឃើញ វាធ្វើសកម្មភាពជាមួយឈ្មោះ ហេង និងភាឡើយ។

៤.៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]រៈ ហៅ រៈ បានឆ្លើយថា៖ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង០៦ល្ងាច ខ្លួននិងបក្ខពួកប្រហែល១០នាក់ បានជួបជុំគ្នាប្រើប្រាស់ថ្នាំញៀន នៅក្នុងផ្ទះសំណាក់នាគមិត្ត ក្រោយពេលប្រើប្រាស់ថ្នាំញៀនរួច ខ្លួននិងបក្ខពួកក៏បានជិះម៉ូតូដើរលេង ក៏បានជួបជនរងគ្រោះ កំពុងជិះ



Scanned with CamScanner

ម៉ូតូតែម្នាក់ឯង និងបក្ខពួកក៏ធ្វើសកម្មភាពប្លន់យកម៉ូតូជនរងគ្រោះតែម្នាក់ឯង។ ឈ្មោះ ហុង ភេទប្រុស អាយុ១៧ឆ្នាំ មានទីលំនៅផ្ទះជួលម្តុំផ្សារ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ និងឈ្មោះ ក្អិត ភេទប្រុស អាយុប្រហែល២៣ឆ្នាំ ស្នាក់នៅផ្ទះជួលម្តុំផ្សារសាំហាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ។ ចំពោះឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច កន្លងមកខ្ញុំពុំដែលស្គាល់ និងឃើញវាទេ ហើយនៅថ្ងៃកើតហេតុនោះ គឺពុំបានឃើញ វាធ្វើសកម្មភាពជាមួយឈ្មោះ ហេង និងភាឡើយ។

៤.៤.តាមចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted] សុវណ្ណ ហៅ ហ្គិច បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្ញុំនៅផ្ទះ ពុំបានចូលរួមធ្វើកម្មភាពជាមួយពួកនោះទេ។ ចំពោះឈ្មោះ [redacted] វង្ហា ហៅថា ឈ្មោ[redacted]: ហៅ វះ ឈ្មោះ [redacted] ហេង ហៅ ស្រីហេង, ឈ្មោះ [redacted] សុភា ហៅ ភា, ឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង, ឈ្មោះ [redacted] ស្វិត ហៅ ស្វិត, ឈ្មោះ [redacted] សុភក្តិ ហៅ ធូ ,ឈ្មោ[redacted] ផានិត ហៅ ក្អិត ខ្ញុំបាទពុំស្គាល់ពួកគេនោះទេ។ ខ្ញុំមានតែឪពុកម្តាយរបស់ខ្ញុំទេ ដែលជាសាក្សីអាចបញ្ជាក់ថាខ្ញុំមិនបានចូលរួមធ្វើសកម្មភាពជាមួយពួកនោះ។

៤.៥.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ចំពោះការចោទប្រកាន់របស់តំណាងអយ្យការនេះ ខ្លួនពុំទទួលយកទេ ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ នៅយប់ថ្ងៃកើតហេតុថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ខ្លួននៅសម្រាក់នៅផ្ទះ ដោយពុំបានចេញដើរលេងជាមួយក្រុមនេះទ។ ហើយកន្លងមកខ្លួនជាមួយនឹងក្រុមនេះ ពុំដែលមានទំនាក់ទំនងអ្វីនឹងគ្នាឡើយ។ រាល់ព្រឹកចាប់តាំងពីម៉ោង៣ទាប់ភ្លឺ ខ្លួនត្រូវដើបចាក់កជ្រូក កោសជ្រូកទុកលក់ជូនអាជីវករ ពុំដែលមានពេលទំនេរនោះទេ។ ម្យ៉ាងទៀតការដែលតុលាការធ្វើការចោទប្រកាន់នោះក៏ពុំចំឈ្មោះ របស់ខ្លួនដែរ គឺតុលាការចោទលើឈ្មោះ [redacted] លីហេង ហៅ ហាង ចំណែកខ្លួនឈ្មោះ [redacted] លីហ៊ាង ភេទប្រុស អាយុ២២ឆ្នាំ។ ខ្លួនមានសាក្សីពីរនាក់ឈ្មោះ [redacted] ថាវី ភេទប្រុស អាយុប្រហែល២៧ឆ្នាំ និងឈ្មោ[redacted] គី ភេទប្រុស អាយុប្រហែល៣៥ឆ្នាំ ដែលបញ្ជាក់ថាយប់កើតហេតុខ្លួន និងពួកគាត់ពិតជានៅកន្លែងធ្វើជ្រូកជាមួយគ្នា។ ខ្លួនសុំឱ្យតុលាការធ្វើការលើកលែងចោទប្រកាន់លើខ្លួន។

៤.៦.តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត បានឆ្លើយថា៖ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល០៦ និង០០នាទី មុនពេលកើតហេតុ នៅពេលទាបភ្លឺថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ខ្លួនជិះម៉ូតូតែម្នាក់ឯងម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ លេខតួ+លេខម៉ាស៊ីន ៩៧៧៩៦៣៥ ពាក់ស្លាកលេខកណ្តាល 1W-0477 ដែលជាកម្មសិទ្ធិរបស់ខ្លួន ទិញយកមកប្រើប្រាស់បន្ត ចេញពីបន្ទប់ជួលក្នុងគោលបំណងទៅបំរើការងារជាកម្មករឡឥដ្ឋម្តុំព្រែកអញ្ចាញ (ខេត្តកណ្តាល) ពេលធ្វើដំណើរតាមផ្លូវទំនប់កប់ស្រូវ (មហាវិថីឈ្នះ១) ពីទិសខាងលិចទៅខាងកើត មកដល់ម្តុំសាលាបឋមសិក្សាត្រពាំងវាំង ភូមិត្រាំងរាង សង្កាត់ឃ្មួញ ខ្លួនបានក្រឡេកមើលមកក្រោយឃើញមានម៉ូតូចំនួន០៥គ្រឿងបិតភ្លើងអំពូលម៉ូតូតាមពីក្រោយមកកៀក ភ្លាមនោះមានម៉ូតូចំនួន០១គ្រឿង ម៉ាកសេ១១០ ជិះគ្នាពីរនាក់មកទន្ទឹមម៉ូតូរបស់ខ្លួនខាងឆ្វេងដៃ ហើយអ្នកក្រោយបានដកដាវប្រហែលកន្លះម៉ែត្រ លើកមកកកាប់លើខ្លួនត្រូវចំកណ្តាលខ្នងចំនួនពីរកន្លែង តែមិនរបួសធ្ងន់ទេ គ្រាន់តែមានស្នាមផ្ទុត ខ្លួនមានអារម្មណ៍ភ័យខ្លាំង ក៏ផ្តួលម៉ូតូទៅលើផ្លូវជាតិ រួចខ្លួនបានរត់គេចខ្លួន ហើយក្រឡេកក្រោយឃើញបក្ខពួកលើកយកម៉ូតូរបស់ខ្លួននាំគ្នាជិះទៅមុខគេចខ្លួនចូលភ្នំពេញបាត់ទៅ ទើបខ្លួនមកស្វែងរកសមត្ថកិច្ចដាក់ពាក្យបណ្តឹងជួយស្រាវជ្រាវតែម្តង។ អំពីភិនភាគជនល្មើស ១.ម៉ូតូម៉ាកសេ១១០ (សង់ប៊ិច) ជិះគ្នាពីរនាក់ធ្វើសកម្មភាព ២.ម៉ូតូម៉ាក ស្មាក់ ពណ៌ខ្មៅ ជិះគ្នាពីនាក់បិតគូថ ៣.ម៉ូតូម៉ាកស្កុបពី ពណ៌ស ជិះគ្នាពីរនាក់បិតគូថ ៤.ម៉ូតូម៉ាក សេ១២៥ ពណ៌ខ្មៅ ជិះគញ្ញាពីរនាក់បិតគូថ និង៥.ម៉ូតូម៉ាក សេ១២៥ ពណ៌ខ្មៅ ជិះគ្នាពីរនាក់បិតគូថ។

៤.៧.តាមការឆ្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ និងឈ្មោ[redacted] លីហ៊ាង ហៅ ហ៊ាង គ្រាន់តែជាការឆ្លើយដោះសារយករួចខ្លួនពីការចោទប្រកាន់តែប៉ុណ្ណោះ ពុំមានភស្តុតាង និងសាក្សីណាមួយ



Scanned with CamScanner

ដើម្បីដោះបន្ទុកពីការចោទប្រកាន់ឡើយ។ ដោយផ្អែកតាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែលកើតមានឡើង សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] វង្ឍា ភេទប្រុស អាយុ១៨ឆ្នាំ ,ឈ្មោះ [redacted] រ: ហៅ រ: ភេទប្រុស អាយុ២៨ឆ្នាំ ,ឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ ,ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ២៦ឆ្នាំ, ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] លីប៉ាង ហៅ ប៉ាង ភេទប្រុស អាយុ២២ឆ្នាំ , ឈ្មោះ [redacted] ស្ទិត ហៅ ស្ទិត ភេទប្រុស អាយុ២៣ឆ្នាំ, ឈ្មោះ [redacted] សុភក្តិ ហៅ ធូ ភេទប្រុស អាយុ២៣ឆ្នាំ , ឈ្មោះ [redacted] ផានិត ហៅ ភ្និត ភេទប្រុស អាយុ២៣ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។

៤.៨.តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៥៣០ រ.វ.ត ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ រួមមាន៖ ទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក OPPO ពណ៌ទឹកមាស (មិនដំណើរការ)។ ម៉ូតូមួយគ្រឿងម៉ាកហុងដា សេ ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១១ ពាក់ស្លាកលេខភ្នំពេញ 1BA-6484 (មិនប្រក្រតី)។

៤.៩.តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ចែងថា អំពើលួច គឺជាអំពើដកហូតដោយចេតនាទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ តាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ៖ អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។

៤.១០.អំពីសមត្ថភាពនៃការទទួលខុសត្រូវ: តាមសាវតារជាតិជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] វង្ឍា ភេទប្រុស អាយុ១៨ឆ្នាំ, ឈ្មោះ [redacted] រ: ហៅ រ: ភេទប្រុស អាយុ២៨ឆ្នាំ, ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ២៦ឆ្នាំ, ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] លីប៉ាង ហៅ ប៉ាង ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] ស្ទិត ហៅ ស្ទិត ភេទប្រុស អាយុ២៤ឆ្នាំ និងឈ្មោះ ហុង ភេទប្រុស អាយុ១៧ឆ្នាំ នៅគ្រប់នីតិវិធី និងនាពេលសវនាការឃើញថាជនជាប់ចោទរូបនេះ មានស្មារតីល្អ មិនមានវិបល្លាសស្មារតីឡើយ។ ហេតុដូច្នេះតុលាការអាចចេញសេចក្តីសម្រេចផ្តន្ទាទោសលើជនជាប់ចោទរូបនេះបាន។

៤.១១.អំពីវត្ថុចាប់យក៖ វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៥៣០ រ.វ.ត ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ រួមមាន៖ ទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក OPPO ពណ៌ទឹកមាស (មិនដំណើរការ)។ ម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១១ ពាក់ស្លាកលេខភ្នំពេញ 1BA-6484 (មិនប្រក្រតី) គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ តាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.១២.អំពីរបបនៃការប្រកាសទោស៖ ជនជាប់ចោទទាំងប្រាំបួនរូប ត្រូវបានរកឃើញថា បានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស បទល្មើសនេះជាបទឧក្រិដ្ឋ តម្រូវឱ្យផ្តន្ទាទោសមូលទោស ដោយដាក់ពន្ធនាគារតែមួយមុខតែប៉ុណ្ណោះ។

៤.១៣.មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ ជនជាប់ចោទឈ្មោះ [redacted] វង្ឍា ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] រ: ហៅ រ: ភេទប្រុស អាយុ២៨ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខ

សាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ២២ឆ្នាំ ,ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ២៦ឆ្នាំ, ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទប្រុស អាយុ២៣ឆ្នាំ, ឈ្មោះ [redacted] សុភក្តី ហៅ ធូ ភេទប្រុស អាយុ២៣ឆ្នាំ ,ឈ្មោះ [redacted] ផានិត ហៅ ភ្និត ភេទប្រុស អាយុ២៣ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.១៤.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឡុង ស៊ីណាត ភេទប្រុស អាយុ៣១ឆ្នាំ ពុំបានចូលខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ក៏ដូចនៅពេលអង្គសវនាការនេះដែរ ដើម្បីប្តឹងទាមទារសំណងរដ្ឋប្បវេណីឡើយ ហេតុដូច្នេះតុលាការពុំគប្បីលើកយកបញ្ហាសំណងរដ្ឋប្បវេណីមកពិចារណា និងសម្រេចឡើយ។

## ៥.ហេតុដូច្នេះសម្រេច

៥.១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ ហៅ ហ្គិច** ភេទប្រុស អាយុ២២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ តាមមាត្រា៣៥០ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥.២.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] **រ: ហៅ រ:** ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥.៣.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **លីហ៊ាង ហៅ ហ៊ាង** ភេទប្រុស អាយុ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ តែព្យួរទោសធម្មតា ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥.៤.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ហេង ហៅ ស្រីហេង** ភេទប្រុស អាយុ២៦ឆ្នាំ, ឈ្មោះ [redacted] **សុភា ហៅ ភា** ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] **ស្វិត ហៅ ស្វិត** ភេទប្រុស អាយុ២៣ឆ្នាំ, ឈ្មោះ [redacted] **សុភក្តី ហៅ ធូ** ភេទប្រុស អាយុ២៣ឆ្នាំ ,ឈ្មោះ [redacted] **ផានិត ហៅ ភ្និត** ភេទប្រុស អាយុ២៣ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់**



Scanned with CamScanner

ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្ទះវិមានល្អះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥.៥.បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]ហេង ហៅ ស្រីហេង, ឈ្មោ[redacted]សុភា ហៅ ភា , ឈ្មោះ[redacted] ស្ទិត ហៅ ស្ទិត, ឈ្មោះ [redacted] សុភក្តិ ហៅ ធូ ,ឈ្មោះ[redacted]ដានិត ហៅ ក្អិត តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥.៦.វត្ថុតាងចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងយកលេខ ១៥៣០ រ.វ.ត ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ រួមមាន៖ ទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក OPPO ពណ៌ទឹកមាស (មិនដំណើរការ)។ ម៉ូតូមួយគ្រឿងម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១១ ពាក់ស្លាកលេខភ្នំពេញ 1BA-6484 (មិនប្រក្រតី) សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

៥.៧.ពិរុទ្ធជនឈ្មោះ [redacted] វដ្ឋា ,ឈ្មោះ [redacted]រៈ ,ឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច មានសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។ ជនជាប់ចោទឈ្មោ[redacted]ហេង ហៅ ស្រីហេង, ឈ្មោ[redacted]សុភា ហៅ ភា, ឈ្មោះ [redacted]លីប៊ាង ហៅ ប៊ាង, ឈ្មោះ [redacted] ស្ទិត ហៅ ស្ទិត, ឈ្មោះ [redacted] សុភក្តិ ហៅ ធូ ,ឈ្មោះ[redacted]ដានិត ហៅ ក្អិត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឡុង ស៊ុណាត មានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ,ឈ្មោះ[redacted]រៈ ,ឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ហេង ហៅ ស្រីហេង, ឈ្មោះ[redacted] សុភា ហៅ ភា, ឈ្មោះ [redacted] លីប៊ាង ហៅ ប៊ាង, ឈ្មោ[redacted]ទិត ហៅ ស្ទិត, ឈ្មោះ[redacted] សុភក្តិ ហៅ ធូ ,ឈ្មោះ[redacted] ដានិត ហៅ ក្អិត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ស៊ុណាត។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ថ្ងៃអង្គារ ៣ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៣ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner